# ជួយអ្នកឯទៀតឱ្យធ្វើតាមព្រះហឫទ័យនៃព្រះ

*ហេតុអ្វីអ្នកគួរប្រាប់អ្នកឯទៀតអំពីអ្វីៗដែលអ្នកកំពុងរៀន? (១)*

*តើអ្នកអាចនិយាយប្រាប់ដំណឹងល្អនេះដល់អ្នកណាខ្លះ? (២)*

*តើគំនិតមារយាទរបស់អ្នកអាចមានអនុភាពយ៉ាងណាលើអ្នកឯទៀត? (២)*

*តើពេលណាទើបអ្នកអាចផ្សាយប្រកាសជាមួយក្រុមជំនុំ? (៣)*





១. មកដល់ពេលនេះ អ្នកបានរៀនរបស់ល្អជាច្រើនពីព្រះគម្ពីរហើយ ។ ចំណេះនេះគួរនាំអ្នកឲ្យបណ្ដុះបុគ្គលិកលក្ខណៈគ្រីស្ទាន ។ (អេភេសូរ ៤:២២-២៤) ចំណេះបែបនេះគឺសំខាន់ណាស់ ដើម្បីឲ្យអ្នកទទួលជីវិតអស់កល្បជានិច្ច ។ (យ៉ូហាន ១៧:៣) ប៉ុន្តែ មានអ្នកឯទៀតដែរ ដែលត្រូវការដឹងឮនូវដំណឹងល្អនេះ ដើម្បីគេអាចទទួលសេចក្ដីសង្គ្រោះផង ។ គ្រីស្ទានពិតទាំងអស់គ្នាត្រូវតែធ្វើបន្ទាល់ដល់អ្នកឯទៀត ។ នេះគឺជាបញ្ញានៃព្រះ ។—រ៉ូម ១០:១០; កូរិនថូសទី១ ៩:១៦; ធីម៉ូថេទី១ ៤:១៦

២. អ្នកអាចចាប់ផ្ដើមដោយនិយាយប្រាប់ពួកអ្នកដែលនៅជិតអ្នកអំពីរបស់ដ៏ល្អដែលអ្នកកំពុងរៀន ។ ប្រាប់របស់ទាំងនេះដល់គ្រួសារ មិត្តភក្ដិ សិស្សរួមសាលា និងអ្នកធ្វើការជាមួយគ្នារបស់អ្នក ។ សូមមានចិត្តសប្បុរសនិងអត់ធ្មត់ពេលអ្នកនិយាយប្រាប់ពួកគេ ។ (ធីម៉ូថេទី២ ២:២៤, ២៥) សូមចាំថា មនុស្សតែងតែសម្គាល់មើលគំនិតមារយាទរបស់អ្នកណាមួយជាងស្ដាប់សំដីរបស់គាត់ ។ ដូច្នេះ គំនិតមារយាទរបស់អ្នកអាចទាក់ទាញមនុស្សឯទៀតឲ្យព្រមស្ដាប់ដំណឹងដែលអ្នកផ្សាយប្រកាសប្រាប់ពួកគេ ។—ម៉ាថាយ ៥:១៦; ពេត្រុសទី១ ៣:១, ២, ១៦

៣. ក្រោយមក អ្នកប្រហែលមានគុណសម្បត្តិគ្រប់គ្រាន់ដើម្បីចាប់ផ្ដើមផ្សាយប្រកាសជាមួយក្រុមជំនុំស្មរបន្ទាល់ព្រះយេហូវ៉ាក្នុងតំបន់អ្នក ។ នេះជាជំហានដ៏សំខាន់មួយក្នុងការចំរើនលូតលាស់របស់អ្នក ។ (ម៉ាថាយ ២៤:១៤) ជាការរីករាយម្ល៉េះហ្ន៎ បើអ្នកអាចជួយអ្នកផ្សេងទៀត ឲ្យក្លាយទៅជាអ្នកបំរើព្រះយេហូវ៉ា ហើយឲ្យគេទទួលជីវិតអស់កល្បជានិច្ចផង! —ថែស្សាឡូនីចទី១ ២:១៩, ២០

